**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អគ្គលេខាធិការដ្ឋាន
លេខ:០១១/០៩ របក.អគគ

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ឧសភា ឆ្នាំ ២០០៩
## របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ ឧសភា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតី ទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែង ដូចខាងក្រោម ៖

### ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

#### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារជាន់ខ្ពស់គម្រោងតុលាការគំរូ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ១៥:០០ រសៀល នៅសណ្ឋាគារ អាំងទែរកុង-ទីណាង់តាល់

-ទទួលលិខិតអញ្ជើញជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងសាកលវិទ្យាល័យនាវាចរណ៍កូរ៉េ និងក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីការអភិវឌ្ឍន៍ឧស្សាហកម្មផ្នែកនាវាចរនៅកម្ពុជា និងការចុះអនុស្សារណៈនៃការយោគយល់គ្នា រវាងសាកល-វិទ្យាល័យ នាវាចរណ៍កូរ៉េ និងសាកលវិទ្យាល័យពុទ្ធិសាស្ត្រ ស្តីពីកិច្ចសហប្រតិបត្តិការជាអន្តរជាតិក្រោមអធិបតីភាពឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩។

-ទទួលលិខិតអញ្ជើញមន្ត្រីជំនាញមួយរូប ចូលរួមជាវាគ្មិនកិត្តិយសក្នុងកម្មវិធី សំណេះ-សំណាលតាមទូរស័ព្ទ ក្នុងកម្មវិធីមាគ៌ាច្បាប់នៅកម្ពុជា របស់វិទ្យុ FM១០២ នៃមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ដោយកម្មវិធីសំណេះសំណាលនេះ ក្រោមប្រធានបទ “តុលាការគំរូ” នៅថ្ងៃព្រហស្បតិ៍ ទី២១ ខែឧសភា ឆ្នាំ២០០៩។

-ទទួលលិខិតពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីសុំចុះប្រមូលព័ត៌មាន និងធ្វើសវនកម្មនៅក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សម្រាប់កាលបរិច្ឆេទ ២០០៧-២០០៨ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទីព្រឹក។

-ទទួលរបាយការណ៏ពីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីកិច្ចប្រជុំអន្តរក្រសួង ដើម្បីរៀបចំចងក្រងផែនការសកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣)។

-ទទួលលិខិតអញ្ជើញចូលរួមអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាបន្តលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីការ ប្រែក្លាយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងលើសេចក្តីព្រាងស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះកុសុមៈ គ្រឹះស្ថានជាសាធារណៈរដ្ឋបាល ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៦-២៧ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ៨ៈ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-ទទួលលិខិតអញ្ជើញពីអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដោយអញ្ជើញតំណាងក្រសួង និងក្រុមការងារចូលរួមប្រជុំ ដើម្បីពិភាក្សាលើការរៀបចំចងក្រងផែនការសកម្មភាពអភិបាលកិច្ចទី ៣ (២០០៩-២០១៣) ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០ រសៀល នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី។

-ទទួលលិខិតអញ្ជើញជាកិត្តិយសក្នុងពិធីទទួលជួបឯកឧត្តម Bill Rammell រដ្ឋមន្ត្រីក្រសួងការបរទេស អង់គ្លេស ក្រោមអធិបតីភាពរបស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ១១ៈ៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

### ខ. ការងារកំណែទម្រង់

-បានរៀបចំកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់គម្រោងតុលាការគំរូ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៩ វេលា ម៉ោង ១៥ៈ០០ រសៀល នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។

-ក្រុមគម្រោងនីមួយៗរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំ និងធ្វើផែនការការងារសម្រាប់ឆ្នាំ២០០៩។

### គ. ផ្សេងៗ

-ចូលរួមអង្គប្រជុំអន្តរក្រសួងផ្សេងៗ។

## ២-សន្និដ្ឋាន

ក្នុងខែ ឧសភា ឆ្នាំ ២០០៩ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព គ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់គម្រោងតុលាការគំរូ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៩ វេលាម៉ោង ១៥ៈ០០ រសៀល នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ ដោយមានការចូលរួម ពីតំណាងក្រុមការងារតុលាការគំរូទាំងបួន គឺសាលាដំបូងក្រុងភ្នំពេញ សាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្ត បន្ទាយមានជ័យ និងសាលាដំបូងខេត្តកំពង់ចាម ដោយមានការពិភាក្សា និងការអនុម័តលើផែនការយុទ្ធសាស្ត្ររបស់សាលាដំបូងទាំង ៤ នេះផងដែរ។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ ជាពិសេសក្នុងការរៀបចំមូលដ្ឋានទិន្នន័យស្តីពី មុខងារស្ថាប័នរដ្ឋ

-ត្រៀមរៀបចំសន្និសីទជាតិស្តីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ។

រាជធានី ភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩

អ្នកធ្វើរបាយការណ៍

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**

ហ៊្សឹង សុកុល